

# "សិចផឹង"

## និយមន័យ

**"សិចផឹង"**

"សិចផឹងសំដៅលើដំណើរការដែលបុគ្គលណាម្នាក់មានចេតនាចែកចាយសារឬរូបភាពដែលពាក់ព័ន្ធនឹងផ្លូវភេទដែលផលិតដោយខ្លួនឯង។

រូបភាព ឬ វីដេអូ អាចរួមបញ្ចូលភាពអាក្រាតពាក់កណ្តាលលកាយ ឬភាពអាក្រាតកាយទាំងមូល សកម្មភាពស្រើបស្រាល និង/ឬ សកម្មភាពផ្លូវភេទ ដែលត្រូវបានចែកចាយជាមួយមិត្តប្រុស មិត្តស្រី ឬមិត្តភក្តិផ្សេងទៀត។



## គោលការណ៍ច្បាប់

សិចផឹងមិនត្រូវបានគេចាត់ជាបទល្មើសព្រហ្មទណ្ឌនោះទេ ក្នុងតំបន់ និងគោការណ៍ច្បាប់អន្តរជាតិស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

ប៉ុន្តែទោះជាយ៉ាងណាក្តី ជាទូទៅ "សិចផឹង" ពិតជារំលោភច្បាប់ស្តីពីរូបភាព និងសម្ភារៈអាសអាភាសកុមារ ដោយសារតែវាអាចជាប់ពាក់ព័ន្ធនឹងការផលិត និងការចែកចាយរូបភាពផ្លូវភេទអនីតិជន។

ដោយយោងតាមពិធីសារដែលជាជម្រើសចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រង់ចំណុចការជួញដូរកុមារ (OPSC), រូបអាស និងសម្ភារៈអាសអាភាសកុមារគឺជា "ការបង្ហាញណាមួយ តាមគ្រប់មធ្យោបាយ ដែលកុមារជាប់ពាក់ព័ន្ធជាក់ស្តែងទៅនឹងសកម្មភាពផ្លូវភេទ ឬជាសកម្មភាពដែលគេផលិតហើយមិនមែនជាកុមារពិត ឬជាការបង្ហាញ អំពីផ្នែក ភេទផ្សេងៗរបស់កុមារសម្រាប់គោលបំណងផ្លូវភេទ"។ និយមន័យនេះ អាចរាប់បញ្ចូលទាំង រូបភាព ឬសម្ភារៈផ្សេងទៀតនៃសិចផឹងផងដែរ។

ជាលទ្ធផល បុគ្គលដែលថត និង/ឬ បញ្ជូនសារផ្លូវភេទជាក់ស្តែង អាចត្រូវចោទប្រកាន់ចំពោះការចែកចាយរូបភាព និងសម្ភារៈអាសអាភាសកុមារ។ លើសពីនេះ បុគ្គលដែលទទួលបានរូបភាព និងសម្ភារៈអាសអាភាសកុមារទាំងនោះ អាចត្រូវគេចោទប្រកាន់ពាក់ព័ន្ធនឹងការកាន់កាប់ ឬមើលរូបភាព ឬសម្ភារៈអាសអាភាសកុមារ។

នៅខណៈពេលព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ភាគច្រើន នឹងមិនផ្តន្ទាទោសកុមារចំពោះការជាប់ពាក់ព័ន្ធនឹង "សិចផឹង" ទេនោះ នៅប្រទេសមួយចំនួនកុមារអាចត្រូវបានគេចោទប្រកាន់ក្រោមច្បាប់រូបភាព និងសម្ភារៈអាសអាភាសកុមារ។

*នៅពេលដែលរូបភាព ឬសម្ភារៈទាំងនោះត្រូវបានគេចែកចាយលើអ៊ីនធឺណិត ហើយនោះ គឺវាស្ទើរតែមិនអាចគ្រប់គ្រងបានចំពោះការចែកចាយបន្ត។*



### តើហេតុអ្វីបានជាកុមារចូលរួមក្នុង សិចផឹង ហើយពួកគេចូលរួមដោយរបៀបណា?

- ជាទូទៅកុមារខ្លួនឯង ថតរូបភាព និងចែកចាយរូបភាព **ដោយខ្លួនពួកគេ** ឬ **តាមសំណើ**ពីបុគ្គលណាម្នាក់ផ្សេងទៀត;
- រូបភាព/វីដេអូ អាចត្រូវបានថតដោយប្រើឧបករណ៍ផ្សេងៗគ្នា។ ជាញឹកញាប់ **ទូរស័ព្ទចល័ត**ត្រូវបានគេប្រើប្រាស់ដើម្បីផលិតសម្ភារៈទាំងនោះ ដែលត្រូវបានគេចែកចាយតាមរយៈការផ្ញើសារ ការជជែកកំសាន្តតាមអ៊ីនធឺណិត ឬកម្មវិធី ឬគេហទំព័របណ្តាញសង្គមនានា
- **សម្ភារៈទាំងនោះ ត្រូវបានចែកចាយ**ជាមួយមិត្តប្រុស មិត្តស្រី មិត្តភក្តិផ្សេងទៀត ឬបុគ្គលដែលពួកគេកំពុងទាក់ទងជាមួយលើបណ្តាញអ៊ីនធឺណិត
- **ការជម្រុញទឹកចិត្ត**របស់កុមារចំពោះ "**សិចផឹង**" អាចមានភាពខុសៗគ្នា រួមបញ្ចូលទាំងការពេញចិត្តចំពោះទំនាក់ទំនងផ្លូវភេទ បទពិសោធន៍ ការព្យាយាមទទួលបានការសរសើរ ឬការយកចិត្តទុកដាក់ និង ការបញ្ជាក់អំពីការប្តេជ្ញាចិត្តចំពោះអ្នកណាម្នាក់។ ការជម្រុញទឹកចិត្តរបស់ពួកគេក៏អាចពាក់ព័ន្ធនឹងសម្ពាធពីមិត្តភក្តិផងដែរ។
- "សិចផឹង" ជាបញ្ហាចំបង ព្រោះថា ជាញឹកញាប់កុមារមិនបានយល់ដឹងអំពី**ផលវិបាកដែលអាចកើតមាន**ពីការប្រព្រឹត្តិរបស់ពួកគេ ហើយពួកគេមិនបានចាត់វិធានការនានាដើម្បី**លាក់បាំងព័ត៌មានដែលអាចកំណត់អត្តសញ្ញាណរបស់ពួកគេឡើយ**
- "សិចផឹង" បង្កជាបញ្ហាកាន់តែធ្ងន់ នៅពេលដែលរូបភាព ឬសម្ភារៈដែលបានផលិតទាំងនោះពាក់ព័ន្ធនឹងបទល្មើស ឬការរំលោភបំពាន **សកម្មភាពបទឧក្រិដ្ឋ ឬរំលោភបំពាន** ដូចជាការចូលរួមរបស់មនុស្សពេញវ័យ;
- "សិចផឹង" ធ្វើឱ្យកុមារ**ងាយរងគ្រោះ** ក្លាយជាជនរងគ្រោះនៃ**ការរុកគួន ឬធ្វើបាបខាងផ្លូវភេទ និងការគំរាមតាមអ៊ីនធឺណិត** ហើយពេលខ្លះរូបភាពរបស់ពួកគេត្រូវបានគេថតចម្លង ឬប្រមូលទុកជាមួយរូបភាព និងសម្ភារៈអំពីការរំលោភបំពានកុមារផ្សេងទៀត ។

** សូមមើលតារាងព័ត៌មាន - អំពើជំរិត ឬគំរាមធ្វើបាបខាងផ្លូវភេទ*

## តើលោកអ្នកអាចធ្វើអ្វីខ្លះ?

អប់រំ និងបង្កើនការយល់ដឹងក្នុងចំណោមកុមារ មាតាបិតា និងអ្នកមើលថែទាំកុមារអំពីហានិភ័យ និងផលវិបាកដែលអាចកើតមានពី "សិចផឹង"

ធ្វើការរាយការណ៍នៅពេលលោកអ្នកជួបប្រទះ "សិចផឹង" ឬរូបភាព និងសម្ភារៈអំពីការរំលោភបំពានផ្លូវភេទលើកុមារលើបណ្តាញអ៊ីនធឺណិត។

តស៊ូមតិ និងសហការជាមួយវិស័យឯកជន ដូចជាអ្នកផ្តល់សេវាកម្មអ៊ីនធឺណិត ដើម្បីកំណត់ចរាចរណ៍នៃ "សិចផឹង" ឬសម្ភារៈរំលោភបំពានផ្លូវភេទកុមារតាមអ៊ីនធឺណិត និងតស៊ូមតិជាមួយក្រុមហ៊ុនទូរស័ព្ទចល័ត ដើម្បីអនុវត្តវិធានការត្រឹមត្រូវសម្រាប់ការសហការជាមួយអាជ្ញាធរនានា នៅពេលមានតម្រូវការ (ឧទាហរណ៍ កាចែកចាយទិន្នន័យអ្នកប្រើប្រាស់តាមសំណើភាគីណាមួយជាដើម)។

តារាងព័ត៌មានស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើអ៊ីនធឺណិតនេះផលិតដោយអង្គការ ECPAT អន្តរជាតិ។
ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងផលិតកម្ម ដែលបានផ្តល់ជូនដោយអង្គការ UNICEF។

ecpat unicef unite for children